archive.today
webpage capture

Saved from https://www.vodkhmer.news/2020/05/18/workers-por-sen-chey-district-guard
no other snapshots from this url
Redirected from https://vodkhmer.news/2020/05/18/workers-por-sen-chey-district-guard-front-
no other snapshots from this url
All snapshots from host vodkhmer.news
from host www.vodkhmer.news

24 Apr 2024 03:02:23 UTC

Webpage | Screenshot

share | download .zip | report bug or abuse



# កម្មករនៅខណ្ឌពោធិ៍សែនជ័យនាំគ្នាដេកយាមមុខរោងចក្រ បន្ទាប់ពីថៅកែដឹកអីវ៉ាន់ចេញដោយមិនទាន់បើកប្រាក់ឈ្នួល

ព័ត៌មានជាតិ | ការងារ

លោក យុត សុគន្ធ | ១៨ ឧសភា ២០២០
ម៉ោង ១៦:៣០



កម្មកររោងចក្រកាត់ដេរសម្លៀកបំពាក់ សីពីយ៉ា (SEPIA) នាំគ្នាយាមមុខរោងចក្រ ដោយបារម្ភខ្លាចថៅកែលួចដឹកសម្ភារចេញ នៅយប់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។ (សារព័ត៌មាន រស្មីភ្នំដា RDN Hot News)

កម្មករ-កម្មការិនីបម្រើការងារនៅរោងចក្រកាត់ដេរសម្លៀកបំពាក់ សីពីយ៉ា (SEPIA) នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ បាននាំគ្នាដេកយាមមុខរោងចក្រអស់រយៈពេល ៤ថ្ងៃមកហើយ ដើម្បីទប់ស្កាត់កុំឱ្យថៅកែដឹកសម្ភារចេញ ខណៈក្រុមកម្មករអះអាងថា ថៅកែរោងចក្រនេះនៅជំពាក់ប្រាក់ឈ្នួលរបស់ពួកគេនៅឡើយ។

កម្មករ-កម្មការិនីនៅរោងចក្រ សីពីយ៉ា (SEPIA) ស្ថិតក្នុងភូមិត្រពាំងជ្រៃ សង្កាត់កាកាប បាននាំគ្នាតវ៉ាមុខរោងចក្រតាំងពីថ្ងៃទី១១ ខែឧសភា និងបានសម្រេចដេកយាមមុខរោងចក្រកាលពីថ្ងៃទី១៥ សប្តាហ៍មុននេះ ក្រោយពីឃើញថៅកែដឹកសម្ភារចេញពីរោងចក្រដោយមិនទាន់បើកប្រាក់ឈ្នួលជូនកម្មករ។

កម្មការិនីផ្នែកដេរ អ្នកស្រី សុខ ដាណា ប្រាប់វីអូឌីនៅថ្ងៃនេះថា ថៅកែរោងចក្រ សីពីយ៉ា បានព្យួរការងារកម្មកររយៈពេល ១ខែហើយ ចាប់តាំងពីថ្ងៃទី១៤ ខែមេសាមក ដោយកំណត់ចូលធ្វើការវិញនៅថ្ងៃទី១៨ ខែឧសភានេះ។

កម្មការិនីវ័យ ២៥ឆ្នាំរូបនេះ អះអាងថា ថៅកែមិនទាន់បើកប្រាក់ឈ្នួលឱ្យកម្មករនៅឡើយទេអំឡុងពេលព្យួរការងារនោះ ខណៈដែលថ្ងៃកំណត់បើកប្រាក់ឈ្នួលឱ្យកម្មករ បានរំលងផុតទៅរយៈពេល ៨ថ្ងៃហើយនោះ ហើយថា ថៅកែរោងចក្រក៏នៅជំពាក់ប្រាក់ឈ្នួលកម្មករកន្លះខែមុនព្យួរការងារផងដែរ។

អ្នកស្រី សុខ ណាដា ឱ្យដឹងថា អ្នកស្រីបានឃើញថៅកែលួចដឹកអីវ៉ាន់ និងសម្ភារមួយចំនួនចេញពីរោងចក្រកាលពីម៉ោងជាង ១០យប់ ថ្ងៃទី១៥ ខែឧសភា ប៉ុន្តែ ត្រូវបានរារាំងដោយក្រុមកម្មករ។

> អ្នកស្រីបន្ថែមថា៖ «ពេលថៅកែអត់បើកលុយឱ្យអ៊ីចឹង កម្មករទាំងអស់គ្នាប្រឈមមុខច្រើនណាស់។ កម្មករអត់លុយបង់ថ្លៃផ្ទះ ថ្លៃទឹកភ្លើង ផ្ទុល សម្រាប់ចាយវាយផ្សេងៗ អ្នកខ្លះទៀតគ្នាអត់លុយបង់សងធនាគារ។ អ៊ីចឹងបានជានាំគ្នាតវ៉ារហូតមកដល់ថ្ងៃនេះ ពីព្រោះកម្មករគេអត់ទុកចិត្ត។ ឥឡូវ មានអ្នកដេកយាមមុខរោងចក្រ បារម្ភខ្លាចថៅកែរោងចក្រលួចដឹកអីវ៉ាន់ចេញអស់ទៅ អត់បើកលុយឱ្យពួកយើង»។

លោក ហួន ហ៊ីម ដែលអះអាងថា ជាតំណាងក្រុមកម្មករ បានប្រាប់វីអូឌីថា ពាក់ព័ន្ធរឿងថៅកែបើកប្រាក់ឈ្នួលឱ្យកម្មករយឺតយ៉ាវនេះ ក្រុមកម្មករបានដាក់ពាក្យបណ្តឹងទៅក្រសួងការងារកាលពីថ្ងៃទី១១ ខែឧសភា ឱ្យជួយដោះស្រាយដែរ ប៉ុន្តែ លោកថា មិនទាន់ឃើញក្រសួងការងារកោះហៅតំណាងកម្មករចូលទៅដោះស្រាយឡើយ។

លោក ហួន ហ៊ីម អះអាងថា ក្រោយកម្មករតវ៉ា និងដេកយាមមុខរោងចក្រមិនឱ្យមានការដឹកសម្ភារចេញនោះ គឺខាងរដ្ឋបាលបានសន្យាបើកលុយឱ្យកម្មករ ៥០ភាគរយនៃប្រាក់ឈ្នួលដែលនៅជំពាក់នៅថ្ងៃទី២៥ ខែឧសភា ហើយថា ៥០ភាគរយទៀត នឹងបើកឱ្យនៅថ្ងៃទី២ ខែមិថុនាខាងមុខ។ លោកថា ទោះមានការសន្យាបើកប្រាក់ឈ្នួលឱ្យខ្លះក៏ដោយ កម្មករនៅតែបន្តដេកយាមមុខរោងចក្ររហូតទទួលបានលុយ។

> លោកបន្ថែមថា៖ «ខាងរោងចក្រគេបានសន្យាបើកលុយឱ្យនៅថ្ងៃទី២៥ ខែឧសភា ៥០ភាគរយ ហើយនៅថ្ងៃទី២ មិថុនា ៥០ភាគរយទៀត ប៉ុន្តែ យើងមិនទាន់ដឹងថា តើវាពិតប្រាកដថា បើកឱ្យកម្មករមែនឬក៏អត់? ឥឡូវ កម្មករដេកយាមរាល់ថ្ងៃ ដោយសារគេបារម្ភខ្លាចថៅកែលួចដឹកម៉ាស៊ីនចេញ ហើយអត់បើកប្រាក់ខែឱ្យកម្មករ»។

ប្រធានរដ្ឋបាលរោងចក្រ ស៊ីពីយ៉ា ដែលកម្មករប្រាប់ថាឈ្មោះ ខេន ប្រាប់ថា លោកកំពុងជាប់រវល់ប្រជុំដោះស្រាយវិវាទនេះនៅក្រសួងការងារ មិនអាចឆ្លើយបានទេ។

វីអូឌីមិនអាចទាក់ទងសុំការបកស្រាយពីអ្នកគ្រប់គ្រងទូទៅនៅរោងចក្រ ស៊ីពីយ៉ា លោក ណៃ ឌឿន បានទេនៅថ្ងៃនេះ ដោយទូរសព្ទពុំចូល ប៉ុន្តែ លោកប្រាប់វីអូឌីកាលពីសប្តាហ៍មុនថា រោងចក្របើកលុយឱ្យកម្មករយឺតយ៉ាវ ដោយសារក្រុមហ៊ុនមានបញ្ហាផ្នែកហិរញ្ញវត្ថុ ពោលគឺគ្មានអ្នកបញ្ជាទិញ ហើយអ្នកបញ្ជាទិញមួយចំនួន មិនទាន់សងលុយគ្រឡប់ ក្រោយទទួលបានទំនិញរួចរាល់។

វីអូឌីមិនអាចសុំការឆ្លើយតបពីមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកាន់សំណុំរឿងនៅរោងចក្រ ស៊ីពីយ៉ា នេះ បាននៅឡើយទេនៅថ្ងៃនេះ។

បើតាមលោក ហួន ហ៊ីម រោងចក្រ ស៊ីពីយ៉ា មានកម្មករប្រហែល ៦០០នាក់ ត្រូវបានថៅកែព្យួរការងារទាំងអស់គ្នាតាំងពីថ្ងៃទី១៤ ខែមេសា។ លោកថា លុយ ៧០ដុល្លារដែលរដ្ឋាភិបាលប្រកាសផ្តល់ឱ្យកម្មករអំឡុងពេលព្យួរការងារនោះ គឺកម្មករមិនទាន់ទទួលបាននោះទេ ទាំងលុយ ៣០ដុល្លាររបស់ថៅកែ និងលុយ ៤០ដុល្លាររបស់រដ្ឋាភិបាល។

ពាក់ព័ន្ធករណីកម្មករដេកយាមមុខរោងចក្រនេះដែរ គឺនៅរោងចក្រ ឡាក់ឃី លី សាន់ឡុង ហ្គាមេន (Lucky Ly Sunn Long Garment Co.Ltd) ស្ថិតក្នុងខណ្ឌមានជ័យ ក៏មានកម្មករដេកយាមមុខរោងចក្រដែរ ក្រោយថៅកែលួចដឹកសម្ភារល្អៗអស់ ហើយគេចខ្លួនមិនដោះស្រាយសំណងជូនកម្មករ។

កម្មការិនីផ្នែកដេរ អ្នកស្រី មិត វ៉ាន់នូ ប្រាប់វីអូឌីថា រោងចក្រ ឡាក់ឃី លី សាន់ឡុង មានថៅកែជាជនជាតិចិន និងកម្មករ ៣៤៥នាក់។ អ្នកស្រីថា រហូតមកដល់ថ្ងៃនេះ កម្មករមួយចំនួននៅបន្តដេកយាមមុខរោងចក្រ រង់ចាំការជួយដោះស្រាយពីអាជ្ញាធរពាក់ព័ន្ធ។

មន្ត្រីគ្រប់គ្រងកម្មវិធីការងារ នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ (Central) លោក ឃុន ថារ៉ូ ប្រាប់វីអូឌីកាលពីថ្ងៃទី១៥ ខែឧសភាថា តាមព័ត៌មានដែលលោកទទួលបាន គឺមានរោងចក្រតូចៗប្រហែល ១០ កំពុងឈានទៅរកការបិទទ្វារ ប៉ុន្តែ លោកថា បច្ចុប្បន្ន មានរោងចក្រ ១ ឬ ២ប៉ុណ្ណោះ ដែលប្រកាសបិទទ្វារតាមនីតិវិធីច្បាប់។

---

**រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម**

សូមបញ្ជាក់ថា គ្មានផ្នែកណាមួយនៃអត្ថបទ រូបភាព សំឡេង និងវីដេអូទាំងនេះ អាចត្រូវបានផលិតឡើងវិញក្នុងការបោះពុម្ពផ្សាយ ផ្សព្វផ្សាយ ការសរសេរឡើងវិញ ឬ ការចែកចាយឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរឡើយ។
ស៊ីស៊ីអាយអឹម មិនទទួលខុសត្រូវចំពោះការលួចចម្លងនិងចុះផ្សាយបន្តណាមួយ ដែលខុស នាំឲ្យយល់ខុស បន្លំ ក្លែងបន្លំ តាមគ្រប់ទម្រង់និងគ្រប់មធ្យោបាយ។ ជនប្រព្រឹត្តិ និងអ្នកផ្តល់គំនិត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់កម្ពុជា និងច្បាប់នានាដែលពាក់ព័ន្ធ។

## អត្ថបទទាក់ទង

### សូមផ្ដល់មតិយោបល់លើអត្ថបទនេះ

នាម និងគោត្តម *

សូមវាយបញ្ចូលឈ្មោះរបស់អ្នក

អ៊ីម៉ែល *

សូមវាយអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក...

លេខទូរសព្ទ (មិនចាំបាច់)

បើសិនជាអ្នកចង់ឱ្យខាងក្រុមការងារ វីអូឌី ទាក់ទងទៅអ្នក សូមទម្លាក់លេខទូរសព្ទ ...

មតិយោបល់ *

សូមបញ្ចូលមតិយោបល់សម្រាប់អត្ថបទខាងលើនេះ...

ចុចបញ្ជូន

**ព័ត៌មានថ្មីៗ** | **បោះឆ្នោត**




លោក ហ៊ុន ម៉ាណែត បដិសេធមិនបានចុះហត្ថលេខាជំនួសនាយករដ្ឋមន្ត្រីរឿងផ្ដល់ជំនួយដល់ប្រទេសតួកគីនោះទេ

១២ កុម្ភៈ ២០២៣ ម៉ោង ១៨:១២

ធនាគារជាតិព្រមានវិធានការច្បាប់លើម្ចាស់គ្រឹះស្ថានឥណទានទទួលយកអត្តសញ្ញាណបណ្ណឬសៀវភៅគ្រួសារពីកូនបំណុល

១២ កុម្ភៈ ២០២៣ ម៉ោង ១៣:១៤



ក្រសួងការងារថា ក្រុមហ៊ុន ខេមបូ ហែនសាំ យល់ព្រមទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនកម្មករ

១១ កុម្ភៈ ២០២៣ ម៉ោង ១៦:១៣




អង់គ្លេសសង្ឃឹមថា ការបោះឆ្នោតជាតិខាងមុខនឹងប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងគ្មានការគំរាមកំហែង

១១ កុម្ភៈ ២០២៣ ម៉ោង ១៥:៤៦



ព្រះមហាក្សត្រតែងតាំងសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រលោក សំបូរ មាណ្ណារ៉ា ជាទីប្រឹក្សាលោក ហ៊ុន សែន

១១ កុម្ភៈ ២០២៣ ម៉ោង ១៤:៥៣








VOD

VOD គឺជាស្ថាប័នព័ត៌មានឯករាជ្យដែលផ្តល់ព័ត៌មាន ផលិតកម្មវិធីវិទ្យុ និងការផ្សព្វផ្សាយតាមរយៈគេហទំព័រអ៊ីនធើណេត។


info@vodhotnews.com

+៨៥៥ ២៣ ៧២៦ ៨៤៥ - លេខបន្ទាន់: +៨៥៥ ៩២ ៩២ ១៩ ០២ / +៨៥៥ ៦០ ៥០ ៥០ ៥០

ផ្ទះលេខ១៤A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ



GET IT ON Google Play

Download on the App Store






- ស្វែងរកព័ត៌មាន
- អំពីយើង
- បណ្ណាសាររូបភាព
- ព័ត៌មានជាសំឡេង
- ក្រមសីលធម៌
- ទូរទស្សន៍
- VOD ENGLISH
- ទំនាក់ទំនង
- ទិន្នន័យចាស់ៗ
- ឱកាសការងារ


© ២០២២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម